បណ្ណព័ត៌មានអំពីជំងឺឆ្លង

# ជំងឺ Pneumococcal

*ការឆ្លងបាក់តេរី **pneumococcal** បង្កឲ្យមានជំងឺផ្សេងៗគ្នាមួយចំនួន ដោយមានរួមទាំងជំងឺរលាកស្រោមខួរ រលាកសួត និងរលាកក្រដាសត្រចៀក។ ជំងឺនេះកើតមានរឹតតែទូទៅឡើងនៅក្នុងរដូវរងានិងរដូវផ្ការីក។ កុមារតូចៗ និងមនុស្សចាស់មានគ្រោះថ្នាក់បំផុតក្នុងការកើតជំងឺនេះ។ វិធីព្យាបាលត្រូវឲ្យប្រើថ្នាំអង់ទីប៊ីយោទិក។ ការចាក់ថ្នាំបង្ការរោគអាចបង្ការជំងឺនេះបាន។*

## តើជំងឺ **pneumococcal** គឺជាអ្វី?

ជំងឺ pneumococcal គឺបណ្ដាលដោយការឆ្លងបាក់តេរី *Streptococcus pneumoniae* ។ ការកើតមានជំងឺនេះអាចបណ្ដាលឲ្យកើតរោគផ្សេងៗគ្នា ដោយមានរួមទាំងរោគរលាកសួត រោគអំបៅអំបែក(រលាកក្រដាសត្រចៀក) និងរលាកស្រោមខួរ(រលាកភ្នាសជុំវិញខួរក្បាលនិងខួរឆ្អឹងខ្នង)។

## តើជំងឺនេះមានរោគសញ្ញាអ្វីខ្លះ?

រោគសញ្ញាទាំងឡាយផ្អែកលើកន្លែងកើតជំងឺ និងអាយុរបស់អ្នកកើតជំងឺ។

- រោគរលាកសួតអាចបណ្ដាលឲ្យមានដង្ហើមខ្លីៗ គ្រុនក្ដៅ អស់កម្លាំង មិនឃ្លានចំណីអាហារ ឈឺក្បាល ឈឺទ្រូង និងក្អក។
- រោគអំបៅអំបែកអាចបណ្ដាលឲ្យឈឺ ការក្រញីទាញត្រចៀក គ្រុនក្ដៅ មួម៉ៅ ស្ដាប់មិនច្បាស់ និងជួនកាលវាក្ខុសព្រមទាំងក្អួត។
- រោគរលាកស្រោមខួរអាចបណ្ដាលឲ្យគ្រុនក្ដៅ ឈឺក្បាល រឹងកញ្ចឹងក ចង្អោរ ក្អួត និងវិលមុខ។

## តើជំងឺនេះឆ្លងតាមរបៀបណា?

ជាញឹកញយបាក់តេរីនេះរស់នៅដោយមិនបង្កគ្រោះថ្នាក់អ្វីឡើយនៅក្នុងបំពង់កនៃអ្នកមានសុខភាពល្អ។ នៅពេលម្ដងម្កាលបាក់តេរីនេះនឹងបង្កឲ្យកើតជំងឺណាមួយ។

## តើអ្នកណាខ្លះដែលអាចមានគ្រោះថ្នាក់កើតជំងឺនេះ?

អ្នកមានគ្រោះថ្នាក់បំផុតក្នុងការកើតជំងឺនេះ មានរួមទាំង៖

- កុមារមានអាយុតិចជាងពីរឆ្នាំ
- មនុស្សពេញវ័យដែលមានអាយុចំណាស់
- ជនជាតិដើម Aboriginal និង Torres Strait Islander

- អ្នកកើតជំងឺស្អូត ជំងឺបេះដូង ជំងឺមហារីក ជំងឺតំរងទឹកនោម មេរោគអេដស៍ ឬខ្វះចំណីអាហារ(ឬជីវជាតិ)
- អ្នកដែលបានវះកាត់យកសរីរាង្គអណ្តើកចេញ ឬដែលសរីរាង្គអណ្តើករបស់ខ្លួនមិនដំណើរការបានពេញលេញ។
- អ្នកជក់បារី

ជំងឺ pneumococcal ច្រើនកើតមាននៅក្នុងរដូវរងានិងដើមរដូវផ្ការីក។
ការឆ្លងរាលដាលបានកើតមានឡើងនៅតាមមណ្ឌលថែទាំកុមារ ទីលំនៅថែទាំមនុស្សចំណាស់ និងស្ថាប័នឯទៀត។

## តើវិធីបង្ការជំងឺនេះធ្វើឡើងដោយរបៀបណា?

### កុមារ

ថ្នាំបង្ការោគ pneumococcal ដែលមិនគិតថ្លៃគួរចាក់ឲ្យកុមារទាំងអស់នៅពេលមានអាយុ 2 ខែ 4 ខែ និង 6 ខែ។

ថ្នាំនេះក៏មិនគិតថ្លៃផងដែរសំរាប់កុមារដែលមានអាយុចាប់ពីពីរឆ្នាំទៅប្រាំឆ្នាំ ដែល៖
- កើតមកដោយមានប្រព័ន្ធការពារទប់ទល់រោគទន់ខ្សោយ
- ទទួលថ្នាំជាក់លាក់ ឬការព្យាបាលដោយវិទ្យុសកម្ម
- ជាអ្នកដែលគ្មានសរីរាង្គអណ្តើក ឬដែលសរីរាង្គអណ្តើករបស់ខ្លួនមិនដំណើរការពេញលេញ
- ឆ្លងរោគអេដស៍
- មានជំងឺខ្សោយតំរងទឹកនោមរ៉ាំរ៉ៃ
- មានជំងឺម្យ៉ាងហៅថា Down's Syndrome
- មានជំងឺបេះដូងដោយបង្កឲ្យខ្វះអុកស៊ីហ្សែន ឬមានជំងឺខ្សោយបេះដូង
- កើតមិនគ្រប់ខែដែលមានជំងឺស្អូតរ៉ាំរ៉ៃ
- ជាកូនក្មេងដែលកើតនៅពេលដែលម្តាយមានផ្ទៃពោះតិចជាង 28 អាទិត្យ
- មានជំងឺពីកំណើតដែលមិនឲ្យអ្នកជំងឺស្រូបយកជីវជាតិពីចំណីអាហារបាន (cystic fibrosis)
- មានរោគទឹកនោមផ្អែមដែលពឹងផ្អែកលើអាំងស៊ុយលីន
- មានការធ្លាយជាតិទឹកនៃខួរ
- មានការវះកាត់បង្កើតផ្លូវឈាមពង្វាងក្នុងលលាដ៍ក្បាល (intracranial shunts) ឬការវះកាត់ដាក់ឧបករណ៍ជំនួយស្តាប់ក្នុងត្រចៀក (cochlear implants)។

កុមារដែលមានស្ថានភាពជំងឺដូចខាងលើ គួរចាក់ថ្នាំបង្ការរោគឡើងវិញនៅពេលមានអាយុ 12 ខែ និងចាក់ថ្នាំបង្ការរោគសំរាប់មនុស្សពេញវ័យចំនួនមួយក៏រិតនៅពេលមានអាយុ 5 ឆ្នាំ។ សូមពិភាក្សាជាមួយវេជ្ជបណ្ឌិតក្នុងតំបន់របស់លោកអ្នក។

### ថ្នាំបង្ការរោគ pneumococcal ក៏ឥតគិតថ្លៃផងដែរសំរាប់៖

### មនុស្សពេញវ័យ

- អ្នកមានអាយុចាប់ពី 65 ឆ្នាំឡើងទៅ
- ជនជាតិដើម Aboriginal និង Torres Strait Islander ដែលមានអាយុ 50 ឆ្នាំឡើងទៅ និងអ្នកមានអាយុ 15-49 ដែល៖
  - មានជំងឺបេះដូង តំរងទឹកនោម ឬស្អូត
  - មានជំងឺហឺត ឬទឹកនោមផ្អែម
  - មានប្រព័ន្ធការពារទប់ទល់រោគទន់ខ្សោយដោយសារជំងឺឬការព្យាបាល
  - ជាអ្នកទទួលទានសុរាឬបារីច្រើន

អ្នកខ្លះដែលមានគ្រោះថ្នាក់ខ្ពស់បំផុតក្នុងការកើតរោគធ្ងន់ធ្ងរ  ក៏គួរប្រើថ្នាំព្យាបាលអង់ទីប៊ីយោទិកជាបន្តទៅទៀតផងដែរ។

បើការចាក់ថ្នាំបង្ការរោគគ្រាដំបូងគឺធ្វើទៅនៅពេលមានអាយុ 65 ឆ្នាំ  អ្នកនោះគួរចាក់ថ្នាំបង្ការរោគនេះសាឡើងវិញ នៅពេល 5 ឆ្នាំក្រោយមកទៀត។

ថ្នាំបង្ការរោគក៏គួរចាក់ផងដែរឲ្យអ្នកមានអាយុ 15-64 ឆ្នាំ ដែល៖

- មានប្រព័ន្ធការពារទប់ទល់រោគទន់ខ្សោយដោយសារជំងឺឬការព្យាបាល
- មានការវះកាត់យកសរីរាង្គអណ្ដើកចេញ ឬដែលសរីរាង្គអណ្ដើករបស់ខ្លួនមិនដំណើរការពេញលេញ
- មានជំងឺរ៉ាំរ៉ៃ (ឧទាហរណ៍៖ ជំងឺបេះដូង  តំរងទឹកនោម  សួត  ទឹកនោមផ្អែម  ឬជំងឺពាក់ព័ន្ធនឹងសុរា)
- មានការធ្លាយជាតិទឹកចេញពីខួរ
- ជាអ្នកជក់ថ្នាំជក់ឬបារី

អ្នកទាំងនេះគួរចាក់ថ្នាំបង្ការរោគឡើងវិញនៅពេលមានអាយុ 65 ឆ្នាំ  ឬនៅពេល 10 ឆ្នាំ ក្រោយពីការចាក់ថ្នាំបង្ការរោគលើកដំបូង (មួយណាដែលកើតឡើងក្រោយគេ)។

## តើការវិនិច្ឆ័យរោគធ្វើទៅតាមរបៀបណា?

វេជ្ជបណ្ឌិតលោកអ្នកអាចធ្វើរោគវិនិច្ឆ័យជំងឺ pneumococcal បាន តាមរយៈរោគសញ្ញាទាំងឡាយ ការពិនិត្យរោគ និងតាមរយៈការធ្វើតេស្តខ្លះ។ តេស្តអាចមានរួមទាំងការថតទ្រូងដោយកាំរស្មីអិក្ស  និងការយកសំណាកដើម្បីរកមើលបាក់តេរីនៅក្នុងផ្នែកកើតជំងឺរបស់រាងកាយលោកអ្នក (ឧទាហរណ៍៖ ឈាម ឬសារធាតុរាវនៃខួរ)។

## តើវិធីព្យាបាលជំងឺនេះធ្វើឡើងដោយរបៀបណា?

ការព្យាបាលមានរួមទាំងថ្នាំអង់ទីប៊ីយោទិក  ថ្នាំគ្រប់គ្រងគ្រុនក្ដៅនិងការឈឺចាប់  និងជាតិទឹកដើម្បីបង្ការកង្វះជាតិទឹកក្នុងខ្លួន។

## តើផ្នែកសុខភាពសាធារណៈមានវិធានការឆ្លើយតបអ្វីខ្លះ?

មន្ទីរពិសោធន៍ត្រូវរាយការណ៍ដោយលាក់ការសម្ងាត់នូវករណីនៃជំងឺ pneumococcal ដែលរាតត្បាត (ទីកន្លែងដែលរកឃើញបាក់តេរីនៅក្នុងឈាម ឬ CSF ឬកន្លែងរម្ងាប់មេរោគផ្សេងទៀត)ទៅកាន់ផ្នែកសុខភាពសាធារណៈ (Public Health Unit) ក្នុងតំបន់។ បុគ្គលិកផ្នែកនេះនឹងពិភាក្សាជាមួយវេជ្ជបណ្ឌិតព្យាបាលនិងអ្នកជំងឺ ឬអ្នកថែទាំអ្នកជំងឺ ដើម្បីរកមើលដឹងកត្តាគ្រោះថ្នាក់ទាំងឡាយដែលអ្នកជំងឺអាចមាន និងដើម្បីសាកសួរអំពីប្រវត្តិចាក់ថ្នាំបង្ការរោគ។ ជាធម្មតាអ្នកប៉ះពាល់ជិតស្និទ្ធនឹងអ្នកជំងឺគ្មានគ្រោះថ្នាក់ធំដុំក្នុងការកើតជំងឺទេ ហើយមិនតំរូវឲ្យមានការពិនិត្យតាមដានក្រោយមកទៀតឡើយ។ ព័ត៌មានអំពីចំនួនអ្នកកើតជំងឺ pneumococcal និងកត្តាគ្រោះថ្នាក់របស់អ្នកទាំងនោះ ជួយឲ្យផ្នែកសុខភាពសាធារណៈក្នុងការស្វែងរកវិធីកាន់តែប្រសើរឡើងដើម្បីបង្ការជំងឺនេះ។

**ព័ត៌មានបន្ថែម – ផ្នែកសុខភាពសាធារណៈ (Public Health) នៅក្នុងរដ្ឋ NSW**



**1300 066 055**

**www.health.nsw.gov.au**